ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

លេខ :**១៤៣១/២៣**.......ក.ប/**ខ.ល**

## សារលិខិតអបអរសាទរ

**សូមគោរពជូន**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

នាឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ តាងនាមថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ ភរិយា ព្រមទាំងក្រុមគ្រួសារ សូមសម្ដែងនូវមនោសញ្ចេតនាសប្បាយរីករាយឥតឧបមា និងសូមអបអរសាទរដោយក្ដីគោរពស្រឡាញ់ និងស្មោះស្ម័គ្របំផុត ជូនចំពោះ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** ដែលត្រូវបាន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ប្រោសព្រះរាជទានគោរមងារជា "**សម្ដេចមហាបវរធិបតី**"។

ការប្រោសព្រះរាជទានគោរមងារដ៏ឧត្ដុងឧត្ដមថ្លៃថ្លានេះ គឺពិតជាស័ក្ដិសមជាទីបំផុតចំពោះសមត្ថភាព បទពិសោធន៍ និងស្នាដៃដ៏ធំធេងដែល **សម្ដេចធិបតី** បានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីជាតិ មាតុភូមិ និងប្រជាជនកម្ពុជា ក្នុងនាមជាអគ្គមគ្គុទេសក៍ដ៏ឆ្នើម និងប៉ិនប្រសប់មួយរូបជាពិសេស ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ មានស្មារតីភក្ដីចំពោះរាជបល្ល័ង្ក ការពារ និងគោរពព្រះពុទ្ធសាសនា ការពារយុត្តិធម៌សង្គម ដើម្បីនិរន្តរភាពរាជានិយម នៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមគោរពជូនពរ **សម្ដេចធិបតី** ទទួលបាននូវមហាជោគជ័យក្នុងបេសកកម្មបម្រើជាតិមាតុភូមិ រក្សាសន្តិភាព ស្ថិរភាព និងបន្តដឹកនាំរាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗជាច្រើនបន្ថែមទៀតជូនប្រទេសជាតិ ដឹកនាំប្រទេសជាតិឆ្ពោះទៅកាន់ភាពរុងរឿង និងកាន់រីកចម្រើនលើគ្រប់វិស័យជានិច្ចនិរន្តរ៍តទៅ។

សូម **សម្ដេចធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃ **ចន្ទ ៤រោច** ខែ **ស្រាពណ៍** ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី **៤** ខែ **កញ្ញា** ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩